រាជបណ្ឌិត្យសភាកម្ពុជា
វិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ

*អត្ថបទស្រាវជ្រាវ ស្តីពី*

# ជំនឿអ្នកតានៅក្នុងសង្គមខ្មែរ
## ករណីសិក្សា ៖ ភូមិអង្គត្រាច ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ



*ដោយ ម៉ិល វាសនា*

*មន្ត្រីស្រាវជ្រាវនៃវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈនៃរាជបណ្ឌិត្យសភាកម្ពុជា*

*ខែឧសភា ឆ្នាំ២០១៩*

# ជំនឿអ្នកតានៅក្នុងសង្គមខ្មែរ
# ករណីសិក្សា ៖ ភូមិអង្គត្រាវ ឃុំត្រពាំងធំខាងជើង
# ស្រុកត្រាំកក់ ខេត្តតាកែវ

## សេចក្ដីផ្ដើម

ខ្មែរមានជំនឿលើព្រលឹង វិញ្ញាណ ដែលគេហៅថា ជីវចលនិយម តាំងពីបុព្វសម័យមកម្ល៉េះ។ គេអាចសន្និដ្ឋានបែបនេះ ដោយសារផ្អែកលើសម្ភារៈសក្ការបូជាផ្សេងៗ ដែលគេរកឃើញនៅក្នុងរណ្ដៅសពមនុស្សខ្មែរបុរាណ។ វាជាជំនឿដែលខ្មែរជឿថា គ្រប់អង្គវត្ថុទាំងអស់ ទាំងមនុស្ស សត្វ រុក្ខជាតិ និងវត្ថុមានរូបនៅលើផែនដីនេះគឺមានព្រលឹងមួយនៅជាប់នោះ។ ហេតុនេះហើយទើបយើងឃើញខ្មែរយើងមានដាក់គ្រឿងតង្វាយផ្សេងៗដល់អ្នកស្លាប់ មានជំនឿលើខ្មោច ព្រលឹងដូនតា អារក្ស អ្នកតា សត្វ និងលើធម្មជាតិ ជាអាទិ៍ ដុំថ្ម ភ្នំ ដំបូកខ្ពស់ៗនិងដើមឈើធំៗ។

បច្ចុប្បន្ន ជំនឿបែបនេះនៅបន្តអត្ថិភាពក្នុងជីវិតនិងជីវភាពរស់នៅរបស់ប្រជាជនខ្មែរយ៉ាងខ្ជាប់ខ្ជួននៅឡើយ ជាពិសេសនៅស្រុកស្រែជនបទ។ គេបានបង្កើតនូវរូបតំណាងនិងសង់ជាខ្ទមសម្រាប់ការសែនព្រេននិងបន់ស្រន់ផ្សេងៗ។ ជាក់ស្ដែង នៅភូមិអង្គត្រាវ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ ប្រជាជននៅប្រតិបត្តិជំនឿលើអ្នកតាយ៉ាងខ្ជាប់ខ្ជួននៅឡើយ ជាពិសេសអ្នកភូមិមានវ័យចំណាស់។ ការប្រតិបត្តិជំនឿលើអ្នកតារបស់អ្នកភូមិមានគោលបំណងផ្សេងៗគ្នា ចំពោះអ្នកតាដោយឡែកៗគ្នាទៅតាមមុខងារអ្នកតានីមួយៗ និងទៅតាមតម្រូវការជាក់ស្ដែងរៀងៗខ្លួន ដែលអាចជាតម្រូវការសមូហភាព តម្រូវការគ្រួសារ ឬ តម្រូវការបុគ្គល។ ជាងនេះទៀត អ្នកភូមិដទៃទៀតក្រៅពីអ្នកភូមិអង្គត្រាវក៏មានជំនឿនិងការប្រតិបត្តិលើអ្នកតាក្នុងភូមិនេះដែរ។ នៅភូមិអង្គត្រាវមានអ្នកតាចំនួន៦ ដែលអ្នកភូមិនៅមានការប្រតិបត្តិនៅឡើយ។

អត្ថបទស្រាវជ្រាវនេះនឹងព្យាយាមកំណត់បង្ហាញអំពីតួនាទីរបស់អ្នកតានៅក្នុងភូមិអង្គត្រាវតាមរយៈការប្រតិបត្តិជំនឿរបស់អ្នកភូមិចំពោះអ្នកតានីមួយៗ ហើយក៏នឹងបង្ហាញផងដែរអំពីស្ថានភាពជំនឿរបស់អ្នកភូមិអង្គត្រាវចំពោះអ្នកតានីមួយៗ។

## ទិដ្ឋភាពទូទៅនៃភូមិអង្គត្រាវ

ភូមិអង្គត្រាវមានសណ្ឋានដីខ្ពស់នៅទិសខាងលិច ដោយជាប់នឹងភ្នំជំរីរមៀល ហើយទាបបន្តិចម្ដងៗទៅទិសខាងកើតរហូតស្មើនឹងភូមិដទៃ។ ភូមិអង្គត្រាវមានប្រជាជនចំនួន៣៤៨គ្រួសារនិងមានប្រជាជនចំនួនសរុប ១៤២៤នាក់ លើផ្ទៃដី ៥០០ហិចតា។ ប្រជាជនក្នុងភូមិនេះភាគច្រើនមានអាយុចាប់ពី ១៨ឆ្នាំឡើង ពោលគឺ មានចំនួនដល់ទៅ ៩៨១នាក់។

តាំងពីដើមមក ប្រជាជននៅភូមិអង្គត្រាវមានមុខរបរចិញ្ចឹមជីវិតពឹងផ្អែកជាចម្បងលើការធ្វើស្រែ និង ធ្វើចម្ការ ដោយស្រែធ្វើនៅរដូវវស្សានិងចម្ការធ្វើទៅតាមរដូវពិសេសនៅរដូវប្រាំង។ ពីមុនរបៀបធ្វើស្រែរបស់អ្នកភូមិមានលក្ខណៈជាប្រពៃណី ដោយពឹងលើកម្លាំងមនុស្សនិងកម្លាំងសត្វទាំង

ការភ្ជួររាស់ ដកស្ទូង ច្រូតកាត់ បោកបែនជាដើម។ អំឡុងពេលជិតមួយទសវត្សចុងក្រោយនេះ របៀបធ្វើស្រែចម្ការមានការប្រែប្រួលច្រើនដោយប្រជាជនពុំសូវពឹងផ្អែកលើកម្លាំងមនុស្សនិងសត្វជាធំទៀតទេ តែ គឺពឹងផ្អែកលើគ្រឿងម៉ាស៊ីនមានជាអាទិ៍ គោយន្ត ត្រាក់ទ័រ ម៉ាស៊ីនច្រូត ម៉ាស៊ីនបោកស្រូវជាដើម។ ចំពោះដំណាំ ប្រជាជនក្នុងភូមិនេះចូលចិត្តដាំម្លូច្រើនជាងគេរហូតដល់មានដង្កៅម្លូ[1] នៅក្នុងភូមិនេះចាំប្រមូលទិញម្លូពីអ្នកភូមិទៀតផង។ ក្រៅពីនេះមានប្រជាជនទៅធ្វើការងារតាមរោងចក្រ សំណង់ អង្គការ ឬការងាររាជការ ហើយក៏មានអ្នកទៅធ្វើការជាកម្មករនៅប្រទេសកូរ៉េនិងប្រទេសថៃផងដែរ។

## ជំនឿលើអ្នកតា

អ្នកតាជាពាក្យសម្រាប់ហៅភូតបិសាចប្រុស ឬទេពារក្សប្រុស ដែលមានខ្ទម ឬរោងអាស្រមជាលំនៅ ឬឥតលំនៅយ៉ាងនោះក៏មាន ៖ ខ្ទមអ្នកតា, បន់អ្នកតា[2]។ នៅក្នុងភូមិអង្គត្រាវមានទីតាំងដែលអ្នកភូមិសម្គាល់ថាជាកន្លែងអ្នកតា និង មានរោងអ្នកតាសម្គាល់ជាច្រើនរហូតអ្នកតាខ្លះមានមុខងារសម្រាប់សុំទឹកភ្លៀងផងដែរ។

ពីដើមនៅក្នុងភូមិអង្គត្រាវនេះមានប្រវត្តិរឿងរ៉ាវទាក់ទងនឹងអ្នកតាជាច្រើនដោយអ្នកតាខ្លះមាននៅរក្សាខ្ទមហើយអ្នកតាខ្លះទៀតបានបាត់ខ្ទមខ្លះរកដានមិនឃើញក៏មាន។

បច្ចុប្បន្នក្នុងភូមិអង្គត្រាវមានអ្នកតាចំនួនប្រាំមួយ៖អ្នកតាធក់ អ្នកតាដំបងដែក អ្នកតាសគ្រាជលោកយាយសក់ស អ្នកតាត្រពាំងត្រយឹង អ្នកតាត្រពាំងពងទឹកនិងអ្នកតាគល់[3]។ ក្នុងចំណោមអ្នកតាទាំងប្រាំមួយនេះ មានតែអ្នកតាត្រពាំងពងទឹកនិងអ្នកតាត្រពាំងត្រយឹងប៉ុណ្ណោះដែលប្រជាជនមិនដឹងជាទូទៅ ក្រៅពីនេះប្រជាជនតែងដឹងឮនិងនៅមានជំនឿប្រហាក់ប្រហែលគ្នា[4]។

### ១- អ្នកតាត្រពាំងពងទឹកនិងអ្នកតាត្រពាំងត្រយឹង

អ្នកតាត្រពាំងពងទឹកនិងអ្នកតាត្រពាំងត្រយឹងចាប់កើតមានឡើងប្រហែលក្រោយឆ្នាំ១៩៧៩ ។ អ្នកតាទាំងពីរនេះកើតឡើងពីការឧប្បត្តិកដោយសារពេលក្មេងៗក្នុងភូមិចងគោឱ្យស៊ីស្មៅ កើតមានហេតុភេទចម្លែកចំពោះសត្វគោនោះ ដូចជា ពេលដឹកគោត្រឡប់មកផ្ទះវិញ គោនោះទៅជាឈឺ ឬប្រកាច់ជាដើម។ ដោយឃើញសភាពមិនស្រួលនៃសត្វគោ នោះអ្នកភូមិដែលរស់នៅក្បែរនោះងាកមកគិតរឿងអបិយជំនឿថា ប្រហែលជានៅបរិវេណត្រង់ម្តុំនេះមានអ្នកតាបារមីអ្វីមួយកាន់ជាពុំខាន ដូច្នេះគាត់ក៏ចាប់ផ្តើមនាំគ្នាបែរបន់។ ក្រោយពីបន់ស្រន់រួចមក សត្វគោក៏ប្រែទៅជាបានជាសះស្បើយឡើងវិញ ហេតុនេះអ្នករស់នៅម្តុំនេះក៏ឧបកិច្ចអ្នកតានៅកន្លែងនេះឡើង។

---

[1] សក់ សំអុល អាយុ ៥៣ឆ្នាំ រស់នៅក្នុងភូមិអង្គត្រាវ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ(សម្ភាសថ្ងៃទី៦ ខែសីហា ឆ្នាំ២០១៦)។

[2] វចនានុក្រមខ្មែរ ភ្នំពេញ ឆ្នាំ១៩៦៧ ទំព័រ ១៨៥៥ ។

[3] សក់ បឿន អាយុ ៥៧ឆ្នាំ ប្រធានភូមិអង្គត្រាវ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ (សម្ភាសថ្ងៃទី៦ ខែសីហា ឆ្នាំ២០១៦)។

[4] សៀក ឈួន (ហៅអាចារ្យណុប) អាយុ ៧៩ឆ្នាំ នៅភូមិអង្គត្រាវ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ (សម្ភាសថ្ងៃទី៦ ខែសីហា ឆ្នាំ២០១៦)។

បច្ចុប្បន្ន មានតែអ្នកភូមិដែលរស់នៅក្បែរនោះប៉ុណ្ណោះដឹងឮពីរឿងអ្នកតានេះ។ ពីដើម អ្នកតាទាំងពីរនេះមានខ្ទមសម្គាល់ត្រឹមត្រូវ តែបច្ចុប្បន្នខ្ទមអ្នកតាទាំងពីរនេះបានបែកបាក់អស់ទៅហើយ។ ដោយឡែក ចំពោះជំនឿលើអ្នកតាទាំងពីរនេះគឺថា ទាល់តែមានហេតុភេទអីកើតឡើងប្លែកៗ មានរឿងព្រៃផ្សៃ(អ្នកតាធ្វើ) ទើបអ្នកភូមិដែលមានជំនឿរស់នៅក្បែរនោះទៅបែរបន់ដោយមិនមានការទៅបន់ស្រន់ជាប្រចាំញឹកញាប់នោះទេ[5]។


អ្នកតាត្រពាំងពងទឹកដែលរោងត្រូវបែកខូចអស់


អ្នកតាត្រពាំងត្រយឹងដែលរោងបាក់បែកតែមានជើងធូប

## ២- អ្នកតាដំបងដែក

អ្នកតាដំបងដែកស្ថិតនៅក្នុងព្រៃដំបូកមួយនិងមានខ្ទមថ្មមួយនៅក្នុងដំបូកនោះ។ទីតាំងកន្លែងអ្នកតាដំបងដែកស្ថិតក្នុងដីកម្មសិទ្ធិរបស់លោកពូ ឡាយ គឿន តពីដូនតាមកដែលគាត់ជាកសិកររស់នៅក្បែរនោះដែរ។ គេសម្គាល់ឃើញថា អ្នកតាដំបងដែកតែងធ្វើទុក្ខទោសដល់អ្នកដែលមកធ្វើស្រែនៅក្បែរនេះណាដែលហូបចំណីមិនដាក់ថ្វាយដូចជា កន្លងទៅ អ្នកមកធ្វើស្រែនៅក្បែរអ្នកតាដំបងដែកបានហូបបាយនិងមិនបានដាក់ថ្វាយ រំពេចនោះគាត់ទៅជាឈឺចុកពោះភ្លាមៗទាល់តែបែរបន់ទើបបានជាសះស្បើយឡើងវិញ[6]។


ទីអ្នកតាដំបងដែកហ៊ុមព័ទ្ធដោយវាលស្រែនិងរបងជុំវិញ


ខ្ទមអ្នកតាក្រោយពេលឆ្ការព្រៃដើម្បីធ្វើពិធីសុំទឹកភ្លៀង

---

[5] សក់ បឿន អាយុ ៥៧ឆ្នាំ ប្រធានភូមិអង្គត្រាវ (សម្ភាសថ្ងៃទី៦ ខែសីហា ឆ្នាំ២០១៦)។

[6] ឡាយ គឿន អាយុ ៧១ឆ្នាំ រស់នៅក្នុងភូមិអង្គ (សម្ភាសថ្ងៃ៦ ខែសីហា ឆ្នាំ២០១៦)។

អ្នកភូមិតែងតែប្រារព្ធពិធីសុំទឹកភ្លៀងនៅកន្លែងអ្នកតាដំបងដែកនេះជារៀងរាល់ឆ្នាំ ជាពិសេសពេលណាឃើញដើមឆ្នាំឬកណ្តាលឆ្នាំរាំងភ្លៀងយូរពេក។ តាមទំនៀមមក ទោះបីគេធ្វើពិធីនៅកន្លែងអ្នកតាដំបងដែក ប៉ុន្តែគឺគេតែងតែឧទ្ទិសដល់អ្នកតាធក់ដែលនៅជិតនោះផងដែរ ហើយសំណែនគឺដាក់ថ្វាយទាំងពីរដូចគ្នា។ ដោយឡែក ក្រោយសម័យប៉ុល ពត គ្រឿងសក្ការសម្រាប់ធ្វើក្នុងកិច្ចពិធីសុំទឹកភ្លៀងនៅកន្លែងអ្នកតាដំបងដែកមានតែទៀន ធូប ផ្កា ទឹក ផ្លែឈើ អាហារនិងបង្អែមលាយចម្រុះគ្នាតែប៉ុណ្ណោះ។ ចំណែកអ្នកចូលរួមមានអ្នកភូមិចំណុះជើងវត្តមង្គលមានលក្ខណ៍ និងអ្នកភូមិមកពីព្រៃដក់ពរ ភូមិព្រៃខ្វាវ ភូមិអង្គត្រាវ ភូមិព្រៃព្រាលនិងភូមិពាក់បង្អោង។ បើគិតចំនួនអ្នកចូលរួមសរុបក្នុងការប្រារព្ធធ្វើពិធីសុំទឹកភ្លៀងថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៦ មានចំនួនប្រហែល៦០នាក់[7]។

ចំពោះដំណើរកិច្ចពីធីនៅកន្លែងអ្នកតាដំបងដែក ជាទូទៅគេធ្វើពេលព្រឹកនិងមានរយៈពេលពីរម៉ោង។ យើងឃើញថា នៅម៉ោង៧ឬម៉ោង៨ព្រឹក ប្រជាជនក្នុងភូមិចាប់ផ្តើមមកជួបជុំគ្នាដោយមានការនិមន្តព្រះសង្ឃមកចូលរួមផងដែរ។ បន្ទាប់ពីប្រជាជននិងព្រះសង្ឃបានជួបជុំគ្នាហើយចាស់ៗចាប់ផ្តើមចាត់ចែងចង្ហាន់ប្រគេនព្រះសង្ឃសម្រាប់ឆាន់ពេលព្រឹក។ ចំណែកឯតាៗចាប់ផ្តើមចាប់ម្ហូបអាហារពីថាស់សម្រាប់ដាក់ថ្វាយនៅកន្លែងអ្នកតាធក់មួយថាស់ និងដាក់នៅកន្លែងអ្នកតាដំបងដែកនេះមួយថាស់។ ពេលព្រះសង្ឃកំពុងឆាន់ ឧបាសក ឧបាសិកាសូត្រនមស្ការថ្វាយបង្គំព្រះ(នមស្ការចំពោះព្រះរត្នត្រ័យ)។ បន្ទាប់មកលោកអាចារ្យចាប់ផ្តើមឧទ្ទិសបួងសួងដល់អ្នកតា បារមីទាំងអស់ដែលនៅថែរក្សាទីនេះមកចូលគ្នាជួយដឹកនាំទឹកភ្លៀងប្រោះព្រំដើម្បីស្រោចស្រពដំណាំចម្ការទាំងឡាយរបស់កសិករ។ ចុងក្រោយមានការវេរចង្ហាន់ប្រគេនព្រះសង្ឃ ហើយព្រះសង្ឃចាប់ផ្តើមសូត្រមន្តបង្ហិលអាកាសឱ្យភ្លៀង និងបង្សុកូល។

ទោះជាយ៉ាងណា ពេលធ្វើពិធីម្តងៗ គឺគេក៏តែងបែរបន់ដល់អ្នកតាធក់ដែលនៅក្បែរនេះផងដែរ ប៉ុន្តែគេជ្រើសរើសយកទីតាំងនៅកន្លែងអ្នកតាដំបងដែកសម្រាប់ប្រារព្ធពិធី ហើយសំណែនគឺគេដាក់ថ្វាយទាំងសងខាង ទាំងអ្នកតាធក់ ទាំងអ្នកតាដំបងដែក។

ចំណែកគ្រឿងតង្វាយពីរថាស់ដែលតាចាប់ដាក់ថាស់តាំងពីដំបូងមុនលោកឆាន់សម្រាប់ថ្វាយដល់អ្នកតានោះទាល់តែបួងសួងហើយចប់កិច្ចពិធីទើបគេយកទៅដាក់ថ្វាយនៅកន្លែងអ្នកតា។

ចំពោះការសម្គាល់ឃើញរបស់អ្នកភូមិក្រោយពេលប្រារព្ធពីធីនេះចប់គឺតែងតែមានភ្លៀងធ្លាក់។ បើមិនភ្លៀងពេលថ្ងៃរសៀលក៏ភ្លៀងពេលល្ងាចដែរ។ ជាក់ស្តែងនៅថ្ងៃដែលយើងបានចុះទៅនៅថ្ងៃគេប្រារព្ធពិធីកន្លែងអ្នកតាដំបងដែកនោះគឺពិតជាគួរឱ្យភ្ញាក់ផ្អើល ព្រោះថាបន្ទាប់ពីធ្វើកិច្ចពិធីពេលព្រឹករួចពេលរសៀលក៏មានភ្លៀងធ្លាក់មកដូចការបន់ស្រន់របស់អ្នកភូមិ។ ទោបីនេះជារឿងចៃដន្យឬជាបារមីក្តី ប៉ុន្តែប្រសិនបើការបន់ស្រន់ទៅឃើញមានលទ្ធផលវិជ្ជមាន នោះធ្វើឱ្យអ្នកភូមិកាន់តែមានជំនឿងនិងបន្តប្រតិបត្តិទៅមុខទៀត។

យើងឃើញថា មុនឆ្នាំ២០១៦ កន្លែងប្រារព្ធពិធីសុំទឹកភ្លៀងនៅទីតាំងអ្នកតាធក់នេះមិនទាន់មានសាងសង់ជារោងត្រឹមត្រូវនោះទេ ដោយព្រះសង្ឃដែលនិមន្តមកគង់តែលើកម្រាលផ្ទាល់នឹងដីប៉ុណ្ណោះ។ ដោយមើលឃើញពីប្រសិទ្ធភាពនៃការបួងសួងកន្លងមក ហើយទីតាំងសម្រាប់ប្រារព្ធពិធីនៅ

---

[7] អោន ឆេង អាយុ ៥១ឆ្នាំ អាចារ្យនៅក្នុងភូមិអង្គត្រាវ (សម្ភាសថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៦)។

ទីនេះមិនទាន់មានធ្វើជាកន្លែងត្រឹមត្រូវនៅឡើយ អ្នកភូមិដែលមានជំនឿនិងបានចូលរួមក្នុងពិធីសុំទឹកភ្លៀងចាប់ផ្តើមមូលមតិគ្នាកសាងសាលាធម្មសភានៅកន្លែងអ្នកតាដំបងដែកនេះឡើងដើម្បីងាយស្រួលក្នុងពេលព្រះសង្ឃនិងពុទ្ធបរិស័ទមកចូលរួមធ្វើពិធីម្តងៗមានកន្លែងត្រឹមត្រូវ ហើយម្ចាស់ដីក៏មានការឯកភាពដែរ។ កត្តានេះបានបង្ហាញឱ្យយើងឃើញពីសាមគ្គីភាពរបស់អ្នកភូមិនិងការបន្តមរតកជំនឿអ្នកតានេះនៅតែមានអត្ថិភាព។

**៣- អ្នកតាឆក់**

អ្នកតាឆក់មានចម្ងាយប្រមាណ១០០ម៉ែត្រពីទីកន្លែងអ្នកតាដំបងដែកនិងមានប្រវត្តិយូរយារដូចគ្នា។ បច្ចុប្បន្នកន្លែងអ្នកតាឆក់គឺស្ថិតនៅក្នុងព្រៃដំបូកមួយមានខ្ទមថ្មតែបាក់ដំបូល។ ប្រជាជនមិនដែលប្រារព្ធពិធីផ្សេងៗនៅកន្លែងអ្នកតាឆក់នេះទេ ដោយគ្រាន់តែមានការបែរបន់ម្តងម្កាលដែលចាំបាច់តែប៉ុណ្ណោះ។ បច្ចុប្បន្ន មិនថាតែអ្នកភូមិនៅទីនេះឬអ្នកភូមិមកពីក្រៅនោះទេ ឱ្យតែគេបានមកដល់កន្លែងអ្នកតាឆក់នេះគឺនៅតែខ្លាចមិនហានទៅប៉ះពាល់ធ្វើអ្វីផ្តេសផ្តាស់នៅដំបូកនោះឡើយ។ ចំពោះរឿងរ៉ាវប្រវត្តិអ្នកតាឆក់ ចាស់បុរាណនៅភូមិព្រៃព្រាលតែងដឹងឮស្ទើរគ្រប់គ្នា។

ពីដើមក្នុងគ្រួសារនីមួយៗភាគច្រើនសុទ្ធតែមានគោ ដោយប្រជាជនពឹងផ្អែកលើសត្វគោជាចម្បងក្នុងការធ្វើស្រែចម្ការ។ ដំណាក់កាលពេលនោះ គោតែងតែមានការឈឺថ្កាត់ជាញឹកញាប់ឬក៏បាត់ដោយសារពេលនោះអ្នកភូមិគឺតែងតែលែងគោចោល។ ហេតុនេះ បើមានបាត់គោ នោះអ្នកភូមិគឺមានតែពឹងច្រើនលើការបែរបន់អ្នកតាឆក់ដោយគេមានជំនឿថា អ្នកតាឆក់នេះជាអ្នកឆក់យកគោរបស់គេ។ មិនថាតែចំពោះសត្វគោនោះទេ ប៉ុន្តែក្មេងដែលមានបញ្ហាផ្សេងៗដូចជាឈឺឬមានប្រតិកម្មខុសប្លែកធម្មតា នោះគេក៏មកបន់ស្រន់ដល់អ្នកតាឆក់នេះដែរ[8]។

នៅជំនាន់ប៉ុល ពត មានអ្នកមកក្ជួរគោទឹមគោ ហើយស្រែកជេរគោ រំពេចនោះគេក៏ឃើញហេតុការណ៍កើតឡើងភ្លាមៗដូចជាគោទៅជាខ្ទងកាច់មិនព្រមទឹមក្ជួរ ដោយដឹងហេតុការណ៍អ្នកក្ជួរគោនិងអ្នកទីនោះជួយបែរបន់និយាយសុំខមាលទោសនៅក្នុងចិត្តដោយឧទ្ទិសដល់អ្នកតាឆក់នេះ។ ក្រោយពីការនិយាយបែរបន់ គោនោះក៏ធ្វើការធម្មតាឡើងវិញ។

រហូតដល់បច្ចុប្បន្ននេះ ក្មេងៗដែលយកគោទៅឱ្យស៊ីស្មៅនៅម្តុំនោះហើយបានជេរឬរត់រញ៉េររញ៉ៃឡូឡាកន្លែងអ្នកតាឆក់នេះឬអ្នកទៅធ្វើស្រែហូបបាយនៅក្បែរនោះមិនមានដាក់ថ្វាយចំណីចំណុកនោះ គេនឹងឃើញហេតុកើតឡើងភ្លាមៗ ដូចជាឈឺចុកពោះជាដើម។ ដោយសារតែអ្នកតាទាំងពីរនេះនៅក្បែរគ្នា នោះបើមានការដាក់ថ្វាយតង្វាយតែម្ខាងក៏ឱ្យទុក្ខទោសដល់គេដែរ។ ដូចជាករណី បងស្រីម្នាក់មានចម្ការនៅក្បែរអ្នកតាដំបងដែកពេលហូបបាយ គាត់ភ្លេចដាក់ឬហៅអ្នកតាឆក់។ បន្ទាប់មកគាត់ឈឺប្រហែលមួយអាទិត្យរកមូលហេតុមិនឃើញ ក៏ទៅរកគ្រូមើលទើបដឹងថាទាក់ទងនឹងអ្នកតាដោយគាត់ដាក់ថ្វាយតង្វាយតែនៅកន្លែងអ្នកតាដំបងដែក ភ្លេចដាក់ថ្វាយតង្វាយនៅកន្លែងអ្នកតាឆក់។ ក្រោយមកគាត់ក៏មករកចាស់ទុំដែលរស់នៅក្បែរនេះជួយអុជធូបនិយាយបែរបន់ទើបរូបគាត់បានជាសះស្បើយឡើងវិញ។

---

[8] ឡាយ ភឿន អាយុ ៧១ឆ្នាំ រស់នៅក្នុងភូមិអង្គត្រាវ (សម្ភាសថ្ងៃ៦ ខែសីហា ឆ្នាំ២០១៦)។

ចំពោះវត្ថុដែលគេធ្លាប់យកមកបែរបន់កន្លងមកមានដូចជា ធូប ទេកមួយស្និត ស្លាធម៌ដូងមួយគូ ប្រហុកបាយកក ពៃប្រមុះជ្រូក ពៃរាប ពៃបីរួត បាយសបាយក្រហម ស្លរគ្រាប់[9]។ ក្នុងចំណោមគ្រឿងតង្វាយទាំងអស់នេះ យើងថ្វាយជាគ្រឿងតង្វាយមួយណាក៏បាន ដោយអ្នកតាធក់នេះមិនប្រកាន់នោះទេ។ ទោះយ៉ាងណា គេមិនដែលឃើញអ្នកមកបែរបន់ថ្វាយសំណែនធំដុំជាអាទិ៍ មាន់ឬក្បាលជ្រូកនោះទេ ហើយក៏មានអ្នកខ្លះថា សំណែនធំដុំគឺមិនត្រូវនឹងអ្នកតាធក់នេះផងដែរ។


អ្នកតាធក់ហ៊ុមព័ទ្ធដោយវាលស្រែ


ខ្ទមអ្នកតាធក់ដែលបាក់ដំបូល

ដោយសារតាំងពីដើមរហូតដល់បច្ចុប្បន្ននេះ ពេលមានបញ្ហាដូចខាងលើហើយការកែបែរបន់ទៅឃើញថាសមប្រកប នោះអ្នកភូមិនៅតែមានជំនឿលើអ្នកតាធក់នេះដដែល។ បច្ចុប្បន្ន អ្នកភូមិនៅក្បែរអ្នកតានេះក៏កំពុងរៃអង្គាសគ្នាដើម្បីធ្វើដំបូលរោងអ្នកតាធក់ដែលបាក់បែកនេះឡើងវិញផងដែរ។

### ៨- អ្នកតាសគ្រាជលោកយាយសក់ស អ្នកតាដំបងយក្ស អ្នកតាក្រហម

អ្នកតាទាំងបីនេះស្ថិតនៅក្នុងវត្តសិរីដំណាក់ដូចគ្នា។ ក្នុងចំណោមអ្នកតាទាំងបីនេះ គឺមានតែអ្នកតាសគ្រាជ លោកយាយសក់សទេដែលមានខ្ទម។ ចំណែកឯអ្នកតាក្រហមនិងអ្នកតាដំបងយក្សមិនមានខ្ទមឬរោងសម្គាល់ឡើយ ដោយគេគ្រាន់តែដឹងថា អ្នកតាទាំងពីរនេះស្ថិតនៅជិតស្រះក្នុងបរិវេណវត្តនេះប៉ុណ្ណោះ។ អ្នកតាទាំងបីនេះមានប្រភពមកពីវាលដំណាក់ត្រាចដែលជាទីកន្លែងវត្តសិរីដំណាក់នេះផងដែរ។ អ្នកតាទាំងនេះកើតមានតាំងពីមុនមានអ្នកវិបស្សនានៅទីនេះមកម្ល៉េះ ហើយប្រជាជនមានជំនឿលើអ្នកតានេះណាស់។

[9] សៀក ឈួន (ហៅអាចារ្យ ណុប) អាយុ៧៩ឆ្នាំ រស់នៅភូមិអង្គត្រាវ (សម្ភាសថ្ងៃទី៦ ខែសីហា ឆ្នាំ២០១៦)។



ខ្ទមអ្នកតាសគ្រាជលោកយាយសក់ស

ចំពោះអ្នកតាសគ្រាជ លោកយាយសក់សនេះក៏មានប្រវត្តិធ្លាប់ចូលឱ្យគេស្នងរូបផងដែរ ហើយ អ្នកដែលស្នងរូបអ្នកតាសគ្រាជ លោកយាយសក់សដំបូងគឺលោកតា ឡឹក បន្ទាប់មកគឺលោកតា ដឹម។ ពីដើមមុននឹងចូលរូប គេមានរៀបថ្វាយគ្រឿងរណ្តាប់ផ្សេងៗដូចជាបាយសម្លនិងមានថ្វាយភ្លេង ជាអាទិ៍ ភ្លេងបួងសួង កន្សែងក្រហម ខ្នងភ្នំ សំពៅថយ។ល។ ប៉ុន្តែបច្ចុប្បន្ន មិនមានអ្នកស្នងរូបបន្ត ទៀតនោះទេ។

បច្ចុប្បន្ន គេមានការប្រារព្ធធ្វើពិធីបន់ស្រន់សុំទឹកភ្លៀងនៅកន្លែងខ្ទមអ្នកតាសគ្រាជ លោកយាយសក់សនេះផងដែរ ដោយមានរៀបជាគ្រឿងរណ្តាប់សម្រាប់ធ្វើពិធីមួយចំនួនដូចជា ស្លាធម៌ដូងជមព្រៃ ពៃចែង ពៃរាប ពៃច្រមុះជ្រូក ពៃយោង ច្រមដាក់ទឹក បាយសបាយក្រហម ម្លូបៀកជាដើម។



ពៃយោង



ច្រមដាក់ទឹក



ស្លាធម៌ដូង



ជមព្រៃ



ពែចែង ពែរាប



ពែច្រមុះជ្រូក



បាយស បាយក្រហម



ម្លូបៀក(ខ្វះបារី)

ទោះយ៉ាងណាពីមុន គេប្រារព្ធធ្វើពិធីសុំទឹកភ្លៀងនេះនៅលើភ្នំដំរីរមៀលដែលមានទីតាំងជិតវត្តនេះ។ ក្រោយមកព្រះចៅអធិការវត្តសិរីដំណាក់ក៏បានអញ្ជើញបារមីអ្នកតាចុះមក ដោយយកកន្លែងអ្នកតាសគ្រាជ លោកយាយសក់សនេះធ្វើជាទីតាំងក្នុងការប្រារព្ធពិធីសុំទឹកភ្លៀង។ គេមានជំនឿថា បើមិនប្រារព្ធពិធីសុំទឹកភ្លៀង នោះនឹងមានការរាំងភ្លៀង ហើយបើមានភ្លៀងធ្លាក់មកក្តីគឺកន្លែងនេះតែងតែរាំងភ្លៀងជានិច្ច[10]។

ក្នុងកិច្ចពីធីនេះ យើងឃើញមានការលេងភ្លេងដោយមានអ្នកចូលរូបផងដែរ តែភ្លេងដែលគេលេងនេះជាប្រភេទភ្លេងពិណពាទ្យមិនមែនប្រភេទភ្លេងអារក្សដូចទំនៀមពីដើមនោះទេ។ ក្នុងនោះដែរលោកតាអាចារ្យនិយាយបួងសួងតាមកិច្ចពិធីជាបន្តបន្ទាប់។

---

[10] សំ នេត្រ(ហៅលោកតា ប៉ាក) ព្រះជន្ម ៦៧ឆ្នាំ ព្រះចៅអធិការវត្តសិរីដំណាក់នៅភូមិអង្គត្រាវ (សម្ភាសថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៦)។


លោកតាអាចារ្យកំពុងរៀបរាប់ក្នុងពិធីសុំទឹកភ្លៀង


សកម្មភាពអ្នកតាចូលរូបពេលប្រគុំភ្លេង

ទោះយ៉ាងណា ពេលគេធ្វើពិធីសុំទឹកភ្លៀងនៅកន្លែងអ្នកតាសគ្រាជ លោកយាយសក់សដែលយើងបានទៅឃើញដល់កន្លែងនោះមិនសូវមានប្រជាជនចូលរួមច្រើននោះទេ។ បើគិតចំនួនអ្នកចូលរួមសរុបទាំងអស់គឺមានប្រមាណ៣០នាក់ប៉ុណ្ណោះក្នុងនោះមានគណៈកម្មការអាចារ្យវត្ត ឧបាសក ឧបាសិកាជើងវត្ត ព្រះសង្ឃនិងប្រជាជននៅក្នុងភូមិនេះមួយចំនួន។ មូលហេតុគឺដោយសារ ភាគច្រើននៅពេលផ្តួចផ្តើមធ្វើពិធីនេះឡើងគឺមានការជុំនុំគ្នាតែជាមួយព្រះសង្ឃ អាចារ្យ យាយជី តាជីដែលនៅប្រចាំការក្នុងវត្តប៉ុណ្ណោះ ដោយមិនមានការប្រកាសប្រាប់ប្រជាជនឱ្យបានដឹងជាទូទៅ ឬប្រាប់ពីថ្ងៃកំណត់ត្រឹមត្រូវឡើយ។

ជារួម កិច្ចពិធីសុំទឹកភ្លៀងនៅកន្លែងអ្នកតាសគ្រាជ លោកយាយសក់សនេះ នៅមានរក្សាប្រពៃណីបានច្រើនទាំងគ្រឿងវណ្តាប់ផ្សេងៗនិងដំណើរនៃកិច្ចពិធី។

### ៥- អ្នកតាគល់

អ្នកតាគល់ធ្លាប់មានប្រវត្តិចូលរូបលោកតា ជឹម និងលោកយាយ ភន ដែលជាប្រជាពលរដ្ឋរបស់នៅក្នុងភូមិ ឃុំនេះផងដែរ។ លោកតា ជឹម គឺជួរមេមត់ចេះស្នេហ៍អ្នកតាដោយអ្នកតាណាក៏អាចចូលរូបបានដែរ។ បន្ទាប់ពីតា ជឹម ស្លាប់ទៅ អ្នកតាគល់ក៏មកចូលរូបនឹងលោកយាយ ភន ប៉ុន្តែចូលម្តងម្កាលប៉ុណ្ណោះមិននៅជាប់ដូចជំនាន់លោកតា ជឹម ឡើយ។ បច្ចុប្បន្ន លោកយាយ ភន មានអាយុប្រហែល៧៨ឆ្នាំនិងរស់នៅក្នុងភូមិអង្គត្រាវនេះ។

ចំពោះប្រវត្តិអ្នកតាគល់នេះមានរឿងដំណាលថា មានអន្លង់បុរាណមួយពកដូចជាកន្លែងស្តុកទឹកឬហៅថាថ្លុកទឹកនៅលើភ្នំបរិផង់ក្នុងទឹកដីខេត្តកំពតហើយគេនាំគ្នាហៅថា អន្លង់គល់ ក្រោយមកហៅថា តាគល់។ អ្នកដែលធ្លាប់ទៅរកស៊ីកាប់ឈើនៅលើភ្នំនោះតែងតែសម្រាកហូបបាយទឹកនៅក្បែរអន្លង់នោះ។ ជាមួយគ្នានោះដែរ លោកតា ជឹម ដែលរស់នៅក្នុងភូមិនេះចេះដើរមើលជំងឺអ្នកស្រុកភូមិជាពិសេស គឺអ្នកដែលឈឺមកពីកាប់ឈើនៅភ្នំដោយសារការចាញ់ទឹក ចាញ់ដី ចាញ់អ្នកតាភ្នំ។ ពេលនោះអ្នកតាគល់ក៏ចូលមកនៅនឹងលោកតា ជឹម នេះ។ បន្ទាប់ពីចូលលោកតា ជឹម ហើយ គាត់ក៏ថែរក្សាអ្នកតាគល់នេះដោយមានសង់ពោងអ្នកតានៅរហូតដល់សព្វថ្ងៃ។ អ្នកតាគល់មកចូលរូបជាមួយលោកតា ជឹម នេះគឺក្រោយឆ្នាំ១៩៧៩។ ចំពោះអ្នកដែលចង់ដឹងពីប្រវត្តិអ្នកចូលរូបគាត់ លោកតា ជឹម តែងនិយាយប្រាប់គេដូចជាប្រវត្តិអ្នកតាគល់នេះជាដើម។

តាជឹមចេះមើលជំងឺអ្នកភូមិរបៀបគ្រូខ្មែរនិងគ្រូបន់ស្រន់ល្បីល្បាញមួយរូបពិសេសទាក់ទងនឹងខុសអ្នកតា ជំងឺពិសផ្សេងៗ ហើយគាត់ចេះវិជ្ជានេះតាំងពីមុនមានអ្នកតាគល់ចូលមកឱ្យលោកស្នងរូបម្ល៉េះ។

ការមើលជំងឺព្រៃផ្សៃឬអ្នកតាធ្វើគឺលោកតា ជឹម ទៅនិយាយរៀបរាប់និងក្រវាសអង្ករដូចជាគេប្រើពាក្យ *បីព្រះច័ន្ទ* (បីថ្ងៃ)។ បើបីព្រះច័ន្ទអ្នកជំងឺនោះជា នោះគេនឹងសែនថ្វាយទៅតាមការបែបន់របស់គេ។

នៅជំនាន់លោកតា ជឹម ភាគច្រើនគឺប្រុសៗនិងស្ថិតក្នុងមនុស្សវ័យកណ្ដាលជាអ្នកមកបែរបន់ ព្រោះប្រុសៗជាអ្នកទៅរកស៊ីកាប់ឈើនៅក្នុងព្រៃលើភ្នំដែលប្រឈមមុខនឹងការចាញ់អ្នកតា ចាញ់ទឹកដីជាដើម ហើយនៅតំបន់នេះមានអ្នកប្រកបមុខរបររកស៊ីកាប់ព្រៃឈើនៅភ្នំនោះច្រើននាក់។ ចំពោះអ្នកជំងឺដោយសារគ្រោះថ្នាក់ផ្សេងៗដែលបង្កឱ្យមានស្នាមរបួសឬជំងឺគ្រុនធំៗ លោកតា ជឹម មិនមើលនោះទេ ហើយអ្នកជំងឺនោះជាទូទៅគឺត្រូវទៅរកពេទ្យដើម្បីព្យាបាល។

បច្ចុប្បន្នភាគច្រើនអ្នកដែលចូលចិត្តមកបន់អ្នកតាគល់នេះ គឺជាមនុស្សស្រី ហើយមិនចំពោះតែអ្នកក្នុងភូមិអង្គត្រាវនេះទេ ប៉ុន្តែអ្នកមកពីភូមិផ្សេងឬមកពីខេត្ត/ក្រុងខ្លះដែលបានដឹងឮពីអ្នកតានេះក៏មានជំនឿនិងមកបែរបន់ផងដែរ។ ចំណែកការបែរបន់ គឺទាក់ទងនឹងជីវភាពរស់នៅ ការរកស៊ី សុំលាភសក្ការនិងជំងឺផ្សេងៗ។ ចំពោះអ្នកធ្វើអាជីវកម្មផ្សេងៗ គេបន់ឱ្យមានអតិថជនទិញរបស់របរគេច្រើន អ្នកខ្លះក៏មកបន់សុំសេចក្ដីសុខសប្បាយឬពេលកូនចៅសាច់ញាតិគេមានជំងឺបន់ឱ្យអ្នកតាជួយឱ្យជាក៏មាន។ កន្លងមកអ្នកមកបន់ស្រន់ជួនក៏សម្រេចដូចបំណង ហើយជួនខ្លះទៀតក៏មិនដូចអ្វីដែលគេប្រាថ្នាដែរ។ ដោយសារតែការបែរបន់ឃើញនៅមានប្រសិទ្ធភាពខ្លះនេះហើយ ទើបអ្នកស្រុកភូមិចេះតែមករកបែរបន់រហូតបែបនេះ។

ចំពោះសំណែនដែលគេថ្វាយ មិនថាជាសំណែនតូចឬសំណែននោះធំប៉ុណ្ណាក៏ដោយ ក៏អ្នកដែលមកសែនថ្វាយនោះមិនដែលយកត្រឡប់ទៅវិញដែរ ដោយគេរក្សាទុកនៅកន្លែងអ្នកតាគល់នេះតែម្ដង។ ដោយឡែក អ្នកផ្សេងដែលមកចង់សុំយកសំណែននោះគឺត្រូវរង់ចាំដល់អស់កំណាត់ធូបដែលគេដុតនោះផងដែរ។ កន្លងមកអ្នកដែលធ្លាប់ទៅសុំយកសំណែននោះ គឺភាគច្រើនមានតែក្មេងៗនៅក្នុងភូមិអង្គត្រាវនេះ ពិសេសក្មេងៗនៅក្បែររោងអ្នកតាគល់ ដោយគេមិនដែលឃើញមានមនុស្សចាស់ទៅយកនោះទេ។


អ្នកមកបែរបន់អ្នកតាគល់


តង្វាយដែលគេថ្វាយអ្នកតាគល់

ទាក់ទងនឹងការសុំសំណែននេះដែរ មានកូនអ្នកភូមិម្នាក់បានប្រព្រឹត្តមិនសមរម្យតាមទំនៀម ដូចជាមកយកបង្អែម ផ្លែឈើ ដែលមិនទាន់ដល់ពេលកំណត់ត្រឹមត្រូវ ហើយត្រូវអ្នកតាគល់ចូលរូប លោកយាយ ភន នេះស្ដីឱ្យក្មេងនោះចំៗតែម្ដង[11]។

សរុបមកចាប់ពីលោកតា ជឹម បានស្លាប់ទៅ មិនមានអ្នកដើរមើលជំងឺខាងព្រៃផ្សៃដូចជា ចាញ់អ្នកតា ចាញ់ទឹកចាញ់ដីនោះទៀតទេ ហើយការបែរបន់ក៏មានការប្រែប្រួលខ្លះដែរ ដោយបច្ចុប្បន្នគឺមានការបែរបន់ច្រើនទាក់ទងនឹងលាភសក្ការហើយការបែរបន់អ្នកជំងឺគឺបន្ទាប់បន្សំ។ កត្តានេះអាចមកពីពេលបច្ចុប្បន្នមិនមានអ្នកទៅរកស៊ីកាប់ឈើលើភ្នំឬនៅតំបន់ឆ្ងាយហើយវិជ្ជាពេទ្យក៏មានការរីកចម្រើន។

## សេចក្ដីសន្និដ្ឋាន

ការគោរពប្រតិបត្តិរបស់អ្នកភូមិអង្គត្រាវលើអ្នកតាគឺមានគោលបំណងផ្សេងៗគ្នា ទៅតាមតួនាទីរបស់អ្នកតាដោយឡែកៗពីគ្នា។ អ្នកភូមិគោរពប្រតិបត្តិអ្នកតាត្រពាំងពងទឹកនិងអ្នកតាត្រពាំងត្រយឹងក្នុងតួនាទីជាអ្នកជួយឱ្យស្ថានភាពជំងឺបានស្បើយ, អ្នកតាដំបងដែកសម្រាប់ព្យាបាលជំងឺ ហេតុមិនប្រក្រតីផ្សេងៗ និង ការសុំទឹកភ្លៀង, អ្នកតាធក់ សម្រាប់ឃុំគ្រងរក្សានិងព្យាបាលជំងឺចតុបាតទាំងឡាយ, អ្នកតាសគ្រាជ លោកយាយសក់ស អ្នកតាដំបងយក្ស អ្នកតាក្រហម សម្រាប់ការសុំទឹកភ្លៀង និង អ្នកតាគល់ សម្រាប់សុំលាភសក្ការនិងព្យាបាលជំងឺផ្សេងៗ។

បច្ចុប្បន្ន អ្នកភូមិដែលនៅបន្តជំនឿនិងប្រតិបត្តិលើអ្នកតា ភាគច្រើនជាមនុស្សមានវ័យចំណាស់។ ការប្រតិបត្តិបន់ស្រន់សុំព្យាបាលជំងឺមានការស្រុតចុះ តែបានលេចឡើងខាងការសុំលាភសក្ការផ្សេងៗ។ ការបន់ស្រន់អ្នកតាសុំឱ្យបានស្បើយជំងឺមានការស្រុតចុះ ដោយសារអ្នកភូមិដឹងថាពេទ្យអាចព្យាបាលជាសះស្បើយ ហើយការទៅរកពេទ្យទៀតសោតគឺងាយស្រួល មណ្ឌលសុខភាពនៅជិត។ ហេតុនេះការបន់ស្រន់កើតមានតែនៅពេលសភាពជំងឺពិបាកគ្រប់គ្រងប៉ុណ្ណោះ តែក៏នៅតែព្យាបាលនៅមន្ទីរពេទ្យជាចម្បងដដែល។ ដោយឡែកកិច្ចពិធីសុំទឹកភ្លៀងនៅអ្នកតាដំបងដែកនិងអ្នកតាសគ្រាជ លោកយាយសក់ស នៅបន្តប្រតិបត្តិជារៀងរាល់ឆ្នាំនៅឡើយ ដោយមានការចូលរួមពីអ្នកភូមិក្បែរភូមិអង្គត្រាវផងដែរ។

វាជាតក្កភាព នៅពេលប្រជាជន ជាពិសេសយុវជនក្មេងៗ មានស្ថានភាពចំណេះដឹងនិងបច្ចេកវិទ្យាទូលំទូលាយ អាចគ្រប់គ្រងស្ថានភាពជុំវិញខ្លួននិងខ្លួនឯងផ្ទាល់បានច្រើន នោះជំនឿអរូបិយផ្សេងៗ ជាអាទិ៍ ជំនឿលើព្រលឹងអ្នកតា ជាដើម នឹងត្រូវធ្លាក់ចុះ។

---

[11] គ្រុត ហាក់ អាយុ ៤២ឆ្នាំ រស់នៅភូមិអង្គត្រាវ (សម្ភាសថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៦)។

## ឯកសារយោង

### កិច្ចសម្ភាសន៍


១- គ្រុត ហាក់ អាយុ ៤២ឆ្នាំ ជាកសិកររស់នៅក្នុងភូមិអង្គត្រាវ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ(សម្ភាសថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៦)។

២- វង់ សុជាវ៉ា ព្រឹទ្ធបុរសដេប៉ាតឺម៉ង់ប្រវត្តិវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ (សម្ភាសថ្ងៃ០៨ តុលា ២០១១)។

៣- សក់ សំអុល ជាប្រជាពលរដ្ឋរស់នៅក្នុងភូមិអង្គត្រាវ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្ត តាកែវ (សម្ភាសថ្ងៃទី៦ ខែសីហា ២០១៦)។

៤- សក់ បឿន ជាប្រធានភូមិអង្គត្រាវ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ (សម្ភាសថ្ងៃ ទី៦ខែ សីហាឆ្នាំ២០១៦)។

៥- សៀក ឈួន(ហៅអាចារ្យណុប) ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ(សម្ភាសថ្ងៃទី ៦ ខែសីហា ឆ្នាំ២០១៦)។

៦- សំ នេត្រ (ហៅលោកតាប៉ាក) ជាចៅអធិការវត្តសិរីជំណាក់នៅភូមិអង្គត្រាវ ឃុំត្រពាំងធំខាង ជើង ស្រុកត្រាំកក់ ខេត្តតាកែវ(សម្ភាសថ្ងៃទី៤ខែសីហា ២០១៦)។

៧- ឡាយ គឿន ជាកសិករស់នៅក្នុងភូមិអង្គត្រាវ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ (សម្ភាសថ្ងៃ៦ ខែសីហា ឆ្នាំ២០១៦)។

៨- អោន ឆេង ជាអាចារ្យចំណុះវេនភូមិព្រៃព្រាលវត្តមង្គលមានលក្ខណ៍បច្ចុប្បន្នរស់នៅក្នុងភូមិអង្គ ត្រាវ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ (សម្ភាសថ្ងៃទី១៣ ខែសីហា ឆ្នាំ ២០១៦)។

៩- វចនានុក្រមខ្មែរ ភ្នំពេញ ១៩៦៧។


### ស្នាដៃនិពន្ធ


១- ខ្លូត ធីតា *ទស្សនវិជ្ជាប្រវត្តិសាស្ត្រខ្មែរសម័យបុរេប្រវត្តិ* នគរភ្នំ និង ចេនឡា ឆ្នាំ២០១៣

២- ត្រឹង ងា *ប្រវត្តិសាស្ត្រខ្មែរ* ភ្នំពេញ ១៩៧៣។

៣- ឃិន គឹមវាណ *ព្រលឹងវប្បធម៌ជម្មជាតិ* ២០០៣។



កិច្ចសម្ភាសជាមួយលោក ឡាយ ភឿន និងភរិយា



កិច្ចសម្ភាសជាមួយលោក ង៉ែត ងឹម និងភរិយា



កិច្ចសម្ភាសជាមួយលោក សក់ សំអុល